SIXTY SIX FINANCE

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក

# របាយការណ៍ប្រចាំឆ្នាំ

# ២០២០

# មាតិកា


**ជំពូកទី I**

### ចំណាប់អារម្មណ៍របស់ថ្នាក់គ្រប់គ្រង
១. ចំណាប់អារម្មណ៍របស់លោកស្រីប្រធាននាយិកាប្រតិបត្តិ
២. ចំណាប់អារម្មណ៍របស់គណៈគ្រប់គ្រង

**ជំពូកទី II**

### អំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក
១. សាវតារបស់គ្រឹះស្ថាន
២. ទស្សនៈវិស័យ និងបេសកកម្ម
៣. គុណតម្លៃ
៤. ទិន្នន័យសំខាន់ៗ
៥. រចនាសម្ព័ន្ធគ្រប់គ្រង

**ជំពូកទី III**

### ការគ្រប់គ្រងផលិតផលឥណទាន
១. ផលិតផល និងសេវាកម្មឥណទាន
២. ការគ្រប់គ្រងហានិភ័យឥណទាន

**ជំពូកទី IV**

### សកម្មភាពបុគ្គលិកប្រចាំឆ្នាំ
១. ការអភិវឌ្ឍន៍ចំណេះជំនាញ និងបង្កើនសមត្ថភាពរបស់បុគ្គលិក
២. ការសហការក្នុងការបំពេញការងារ

**ជំពូកទី V**

### របាយការណ៍សវនកម្មហិរញ្ញវត្ថុ
១. របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
២. របាយការណ៍របស់សវនករឯករាជ្យ
៣. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៤. របាយការណ៍ចំណូលលម្អិត
៥. របាយការណ៍លំហូរសាច់ប្រាក់
៦. របាយការណ៍បម្រែបម្រួលមូលធន
៧. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

# ជំពូកទី ១

## ចំណាប់អារម្មណ៍របស់ថ្នាក់គ្រប់គ្រង

## ១. ចំណាប់អារម្មណ៍របស់ប្រធាននាយិកាប្រតិបត្តិ



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ។ ចាប់តាំងពីពេលដំណើរការ គ្រឹះស្ថានបានផ្តល់នូវសេវាហិរញ្ញវត្ថុដែលមានស្ថេរភាព និរន្តភាព និងការយកចិត្តទុកដាក់ខ្ពស់ដល់អតិថិជនរបស់ខ្លួន ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

ដើម្បីទទួលបានការអភិវឌ្ឍន៍ប្រកបដោយចីរភាព គ្រឹះស្ថានតែងតែស្វែងរកយុទ្ធសាស្ត្រទីផ្សារថ្មីៗ និងខិតខំព្យាយាមពង្រឹងនូវគុណភាពសេវាកម្មរបស់ខ្លួនដល់អតិថិជននូវសេវាកម្មប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្នុងគោលបំណងជម្រុញជីវភាពរបស់ពួកគាត់ឲ្យកាន់តែល្អប្រសើរឡើងជាលំដាប់តាមរយៈសេវាហិរញ្ញវត្ថុ ហើយគ្រឹះស្ថានបន្តរក្សាទំនាក់ទំនងឲ្យកាន់តែល្អប្រសើរថែមទៀតជាមួយអតិថិជន ។

ក្នុងការប្រតិបត្តិអាជីវកម្ម គ្រឹះស្ថានតែងតែគោរព និងអនុលោមយ៉ាងខ្ជាប់ខ្ជួនទៅតាមប្រកាស និងសេចក្តីសម្រេចផ្សេងៗរបស់ធនាគារជាតិ នៃកម្ពុជា ។ នៅក្នុងនោះ មានលិខិតរបស់ធនាគារជាតិលេខ ធ៧-០១៩-១២២ ស.ជ.ណ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយដោយយោងលើលិខិតនេះ គ្រឹះស្ថានក៏បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ ដែលអនុវត្តទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SME) ។

យោងទៅលើលទ្ធផលក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ បង្ហាញឲ្យឃើញថា ស្ថាប័នមានការរីកចម្រើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលឆ្លុះបញ្ចាំងនូវគុណភាពការងារប្រតិបត្តិការ ការប្រឹងប្រែង និងទំនុកចិត្តត្រលប់ពីអតិថិជន ។ លទ្ធផលនៃចំណូលដុល ដែលសម្រេចបាននៅក្នុងឆ្នាំ ២០២០ គឺមានចំនួន ៦៩៨,៤៨ លានរៀល ហើយអតិថិជនសកម្មមាន

ចំនួន ២៥នាក់ សមតុល្យឥណទានសរុបសម្រាប់ឆ្នាំ ២០២០ មានចំនួន ៧.៩២៥,៤៨ លានរៀល ហើយលទ្ធផលដែលល្អប្រសើរមួយទៀត គឺយើងទទួលបានកម្រិតហានិភ័យឥណទានក្នុងអត្រា ០% ។

ដើម្បីក្លាយជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេ និងជោគជ័យក្នុងអាជីវកម្មមួយនេះ យើងបានកំណត់ផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាក់លាក់សម្រាប់ឆ្នាំ ២០២០-២០២៣ ។ បន្ថែមពីលើនេះ យើងនឹងបន្តអភិវឌ្ឍន៍ក្រុមការងារឲ្យពោរពេញទៅដោយចំណេះជំនាញ ការសហការដែលចុះសម្រុងដោយរលូន វប្បធម៌ការងារល្អប្រសើរ ព្រមទាំងបន្តផ្តល់ការលើកទឹកចិត្តដល់បុគ្គលិក ហើយស្ថាប័ននឹងរីករាយទទួលយកនូវគំនិតថ្មីៗរបស់បុគ្គលិក មិតិយោបល់ពីអតិថិជន ដើម្បីការអភិវឌ្ឍន៍ និងបោះជំហានទៅមុខឲ្យឆាប់រហ័ស ។ ក្នុងនោះដែរ ស្ថាប័នគ្រោងនឹងបង្កើតនូវផលិតផលឥណទានថ្មីមួយទៀត គឺប្រភេទឥណទានយានជំនិះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនឲ្យបានទូលំទូលាយជាងមុន ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ប្រធានក្រុមប្រឹក្សាភិបាលដែលបានផ្តល់គំនិត មតិយោបល់ និងវិធីសាស្ត្រផ្សេងៗនាពេលកន្លងមក ។ ហើយក៏សូមអរគុណដល់ការខិតខំប្រឹងប្រែងរបស់ថ្នាក់គ្រប់គ្រង និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ ចំពោះការចូលរួមគាំទ្រ ក៏ដូចជាការសហការគ្នាយ៉ាងសកម្ម ប្រកបដោយឆន្ទៈខ្ពស់ និងភាពស្មោះត្រង់ដើម្បីឲ្យស្ថាប័នរីកចម្រើន ។ ប្រសិនបើគ្មានអ្នកទាំងអស់គ្នានោះទេ ក៏មិនអាចកើតមាននូវសមិទ្ធផលទាំងនេះបានដែរ ។

ខ្ញុំនៅតែសង្ឃឹមយ៉ាងមុតមាំ និងរំពឹងថាអ្នកទាំងអស់គ្នានឹងនៅតែបន្តជួយជ្រោមជ្រែងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ហ្វាយនែន ម.ក ដើម្បីឲ្យក្លាយជាស្ថាប័នឈានមុខគេ ហើយខ្ញុំទន្ទឹងរងចាំការចូលរួមជាមួយអ្នករាល់គ្នា ចំពោះគំនិតច្នៃប្រឌិតថ្មីៗ ដើម្បីសម្រេចតាមផែនការយុទ្ធសាស្ត្រដែលបានព្រៀងទុក ។



លោកស្រី **ហ៊ីង សោភ័ណ្ឌ**

**ប្រធាននាយិកាប្រតិបត្តិ**

## ២. គណៈគ្រប់គ្រង




**លោកស្រី លឹម សាគូ  នាយិកាប្រតិបត្តិតាម**

លោកស្រី **លឹម សាគូ** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសកលវិទ្យាល័យ បៀលប្រាយ ក្នុងឆ្នាំ២០០៦ ។

បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្ររួច លោកស្រីបានចូលបម្រើការងារនៅ ធនាគារ កម្ពុជា អាស៊ី ចំកាត់ រយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០០៨ មានតួនាទីជាបេឡាធិកា ។

ឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៣ លោកស្រីបានចូលបម្រើការងារនៅក្រុមហ៊ុន ហ្គោលឌិន ហ្វធូន អិលធីឌី មានតួនាទីជាបុគ្គលិកផ្នែកលក់ ។

លោកស្រីបានចូលបម្រើការងារនៅ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ អស់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៩ មានតួនាទីជាមន្ត្រីប្រតិបត្តិការសាខា រយៈពេល ១ឆ្នាំ និងមានតួទីជាមន្ត្រីប្រតិបត្តិតាម ជាន់ខ្ពស់រយៈពេល ៤ឆ្នាំ ។

លោកស្រីបានចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ រហូតបច្ចុប្បន្ន មានតួនាទីជា **នាយិកាប្រតិបត្តិតាម** ដើម្បីទទួលខុសត្រូវលើ ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន ដឹកនាំ និងត្រួតពិនិត្យដោយឯករាជ្យលើមុខងារប្រតិបត្តិ ជាមន្ត្រីប្រតិបត្តិ ដែលមានតួនាទីទទួលខុសត្រូវលើការអនុវត្តការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងការងារ ការយកចិត្តទុកដាក់ស្គាល់អតិថិជន ដើរតួនាទីជាអ្នកសម្របសម្រួល និងទំនាក់ទំនងជាមួយ នាយកដ្ឋានសវនកម្ម ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ។




**លោក ឈីវ គោវិទ  នាយកផ្នែកហិរញ្ញវត្ថុ**

លោក **ឈីវ គោវិទ** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០០៤ និង បន្តសិក្សាយកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគណនេយ្យហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង ដោយបានបញ្ចប់ការសិក្សាក្នុងអំឡុងឆ្នាំ២០១៤ ។

បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ លោកបានបានបម្រើការងារនៅធនាគារ អេស៊ីលីដា ភីអិលស៊ី អស់រយៈពេល ១០ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៥ រហូតដល់ឆ្នាំ ២០១៥ ក្នុងមុខងារជាច្រើនដូចជា បុគ្គលិកផ្នែកគណនេយ្យ បុគ្គលិកផ្នែកសវនកម្មហិរញ្ញវត្ថុ បុគ្គលិកផ្នែកគណនេយ្យគ្រប់គ្រង និងជាអ្នកឯកទេសបឋមគ្រប់គ្រងឥណទាន ។

ចាប់ពីដើមឆ្នាំ ២០១៦ រហូតដល់ឆ្នាំ ២០១៩ លោកមានបទពិសោធធ្វើការរយៈពេល ៤ឆ្នាំ នៅបណ្ដាក្រុមហ៊ុន និង គ្រឹះស្ថានហិរញ្ញវត្ថុ ផ្សេងៗក្នុងមុខងារជា នាយកការិយាល័យហិរញ្ញវត្ថុ ។

បច្ចុប្បន្នលោកបានចូលមកបម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក ក្នុងមុខតំណែងជា **នាយកផ្នែកហិរញ្ញវត្ថុ** ចាប់ពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ ដើម្បីទទួលខុសត្រូវក្នុងការរៀបចំការងារផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័នឲ្យមានបែបបទស្តង់ដាត្រឹមត្រូវ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យស្ថាប័នប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព និងការរៀបចំផែនការ យុទ្ធសាស្ត្រនានា ដើម្បីទទួលបាននូវប្រសិទ្ធិភាពនៃការអនុវត្តគោលការណ៍ហិរញ្ញវត្ថុ ។




## លោកស្រី ឈុន សុភា នាយិកាផ្នែកព័ត៌មានវិទ្យា

លោកស្រី **ឈុន សុភា** បានបញ្ចប់ការសិក្សាផ្នែកព័ត៌មានវិទ្យា ថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ Lumière Lyon2 នៃប្រទេសបារាំងនៅឆ្នាំ២០១៥ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មកពីសាកលវិទ្យាល័យ Telecom SudParis នៃប្រទេសបារាំងនិង Asian Institute of Technology នៃប្រទេសថៃនៅឆ្នាំ២០០៩ និងបានបញ្ចប់ការសិក្សាថ្នាក់វិស្វករមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានៅឆ្នាំ២០០៧ ។

បន្ទាប់ពីបញ្ចប់ការសិក្សា ដោយក្នុងគោលបំណងអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា លោកស្រីបានធ្វើការជាគ្រូបង្រៀន ជាអ្នកស្រាវជ្រាវ និងគ្រប់គ្រងគម្រោងផ្សេងៗជាមួយដៃគូរទាំងក្នុងនិងក្រៅប្រទេសនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ។

ដើម្បីផ្លាស់ប្តូរបទពិសោធន៍ បន្តការអភិវឌ្ឍន៍ខ្លួនឯង និងដោយចង់ឃើញពីភាពចម្រើននៃវិស័យហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជា ។ នៅដើមឆ្នាំ២០២០ លោកស្រីបានចូលមកបម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក ក្នុងមុខតំណែងជា **នាយិកាផ្នែកព័ត៌មានវិទ្យា** ។ នៅក្នុងមុខតំណែងនេះ លោកស្រីទទួលខុសត្រូវ លើការគ្រប់គ្រងប្រព័ន្ធផ្សេងៗទាំងអស់ របស់ ស្ថាប័ន ការធានាសុវត្ថិភាពរបស់ប្រព័ន្ធ និងទិន្នន័យ ការរៀបចំផែនការ និងយុទ្ធសាស្រ្តនានាទាក់ទងនឹងផ្នែកព័ត៌មានវិទ្យា ដើម្បីគាំទ្រដំណើរការនិងការអភិវឌ្ឍន៍របស់ស្ថាប័ន ។



**លោកស្រី ទ្រី ថាវី**

**ប្រធានផ្នែកលេខាធិការ**

**លោកស្រី ទ្រី ថាវី ប្រធានលេខាធិការ**

លោកស្រី **ទ្រី ថាវី** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ពុទ្ធិសាស្រ្ត ក្នុងឆ្នាំ ២០១៤ ។ លោកស្រីបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ចាប់តាំងពីឆ្នាំ ២០១២ រហូតដល់ឆ្នាំ ២០១៩ ក្នុងមុខងារតួនាទីដូចជា ហិរញ្ញិក អ្នកបញ្ចូលទិន្នន័យ និងជាមន្ត្រីសេវាអតិថិជន ។

បច្ចុប្បន្នលោកស្រីបានចូលមកបម្រើការងារក្នុងគ្រឹះស្ថាន សុិកធី សុិកស៍ ហ្វាយនែន ម.ក មុខតំណែងជា **ប្រធានលេខាធិការ** ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ ដើម្បីទទួលខុសត្រូវក្នុងការរៀបចំការងារផ្នែកប្រតិបត្តិការរបស់ស្ថាប័នឲ្យមាន បែបបទ ស្តង់ដាត្រឹមត្រូវ និងរៀបចំដឹកនាំការងារក្នុងការបម្រើសេវាជូនដល់អតិថិជនប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈខ្ពស់ ។

# ជំពូកទី ២

## អំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក

## ១. សាវតារបស់គ្រឹះស្ថាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក បានបង្កើតឡើងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ក្រោមបញ្ជីពាណិជ្ជកម្មលេខ ០០០៣៩៧០៣ ។ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ គ្រឹះស្ថានបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ដើម្បីប្រតិបត្តិការជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

ទីស្នាក់ការដែលបានចុះបញ្ជីរបស់ក្រុមហ៊ុនស្ថិតនៅទីតាំង ផ្ទះលេខ៤០ ផ្លូវជាតិលេខ១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់គ្រឹះស្ថានគឺផ្តល់សេវាប្រាក់កម្ចីដល់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ដែលជារូបវន្តបុគ្គល និងនីតិបុគ្គល ។

ចំពោះដើមទុនក្នុងការបង្កើតគ្រឹះស្ថាននេះឡើងគឺរួមមានម្ចាស់ភាគហ៊ុនចំនួនពីររូបរួមមានគឺលោក LEE KOK HENG JEREMIAH និងលោកស្រី ហ៊ីង សោភ័ណ្ឌ ក្នុងចំនួនទឹកប្រាក់សរុប ៣.០០០.០០០ដុល្លារអាមេរិក ។

## ២. ទស្សនវិស័យ និងបេសកកម្ម

### ទស្សនវិស័យ ៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម. ក ជាគ្រឹះស្ថានដែលផ្តល់នូវទំនុកចិត្ត និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជន និងបង្កើនកម្រិតជីវភាពដល់អតិថិជនឲ្យកាន់តែល្អប្រសើរ តាមរយៈការចូលរួមផ្តល់សេវាហិរញ្ញវត្ថុ ។

### បេសកកម្ម ៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក បានកំនត់នូវបេសកកម្មរួចជាស្រេចនូវគោលដៅដើម្បីក្លាយជាស្ថាប័នឈានមុខគេក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុ និងការបម្រើសេវាល្អប្រសើជូនអតិថិជនប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ។

## ៣. គុណតម្លៃ

ផ្តល់នូវសេវាកម្មដ៏ល្អប្រកបដោយវិជ្ជាជីវៈខ្ពស់ទៅដល់អតិថិជន ហើយផលិតផលសេវកម្មឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនផងដែរ ។ បុគ្គលិកទាំងអស់ធ្វើការប្រកបដោយភាពស្មោះត្រង់ និងមានចំណេះជំនាញពិតប្រាកដ និងមានការសហការគ្នាក្នុងការធ្វើការបានយ៉ាងល្អប្រសើរ ។

## ៤. ទិន្នន័យសំខាន់ៗ

| ផ្នែកប្រតិបត្តិការ (ចំនួនទឹកប្រាក់គិតជាដុល្លារ) | ២០២០ | ២០១៩ |
|---|---|---|
| ចំនួនបុគ្គលិក | ១០ | ៨ |
| ចំនួនអតិថិជនសកម្ម | ២៥ | ០ |
| សមតុល្យឥណទានគេហដ្ឋាន | ១,៥៨៨,៥៦៣ | ០ |
| សមតុល្យឥណទានរយៈពេលខ្លី | ០ | ០ |
| សមតុល្យឥណទានរយៈពេលវែង | ៣៧០,៧៦៥ | ០ |
| សមតុល្យឥណទានទិញឧបករណ៍សម្ភារៈ | ០ | ០ |
| សមតុល្យឥណទាននិស្សិត | ០ | ០ |

| ផ្នែកហិរញ្ញវត្ថុ (ចំនួនទឹកប្រាក់គិតជាដុល្លារ) | ២០២០ | ២០១៩ |
|---|---|---|
| ទ្រព្យសកម្ម | ២,៨៨១,២៤៩ | ៣,១១៥,១៧៨ |
| ទ្រព្យអកម្ម | ៣១,០៧៣ | ២០៨,០៤០ |
| ទ្រព្យម្ចាស់ | ២,៨៥០,១៧៦ | ២,៩០៧,១៣៨ |
| ចំណូលការប្រាក់ | ១៥៣,៧៧២ | ៤៩,២៥២ |
| ចំណូលផ្សេងៗ | ១៧,៥៤៩ | ៦០០ |
| ចំណាយប្រតិបត្តិការ និងចំណាយផ្សេងៗ | ២២៨,២៨៣ | ១៤២,៧១៤ |
| ប្រាក់ចំណេញ/ខាត ក្រោយបង់ពន្ធ | (៥៦,៩៦២) | (៩២,៨៦២) |

# ៥. រចនាសម្ព័ន្ធគ្រប់គ្រង



# ជំពូកទី ៣

## ការគ្រប់គ្រងផលិតផល និងសេវាកម្ម

## ១. ផលិតផល និងសេវាកម្មឥណទាន

សម្រាប់ផលិតផលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក គឺផ្តល់ប្រាក់កម្ចី ដែលជាឥណទានផ្តល់ទៅឲ្យអតិថិជនទូទៅទាំងរូបវន្តបុគ្គល និងនីតិបុគ្គលិក ទៅតាមតម្រូវការផ្សេងៗ ។

- អតិថិជនជារូបវន្តបុគ្គល គឺជាឯកត្តជនទាំងឡាយណាដែលមានតម្រូវការឥណទានដើម្បីបំពេញតម្រូវការផ្ទាល់ខ្លួន ដូចជា ឥណទានគេហដ្ឋាន ឥណទានរយៈពេលខ្លី ឥណទានរយៈពេលវែង ឥណទានសម្រាប់ទូទាត់ទំនិញ និង ឥណទានសម្រាប់និស្សិតយកទៅបន្តការសិក្សា ។
- អតិថិជនជានីតិបុគ្គល គឺជាសហគ្រាសខ្នាតតូចបំផុត ខ្នាតូច និងមធ្យម និងក្រុមហ៊ុនទាំងឡាយណាដែលមានតម្រូវការសាច់ប្រាក់យកទៅធ្វើទុនបង្វិលក្នុងការប្រតិបត្តិការអាជីវកម្ម រួមទាំងការបង្កើតអាជីវកម្មថ្មី និងក្នុងគោលបំណងពង្រីកអាជីវកម្មរបស់ខ្លួនដែលមានស្រាប់ ។

ផលិតផលឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក មានចំនួន ៥ ប្រភេទ គឺ ឥណទានគេហដ្ឋាន ឥណទានរយៈពេលខ្លី ឥណទានរយៈពេលវែង ឥណទានសម្រាប់ទូទាត់ទំនិញ និង ឥណទាននិស្សិត ។

### ១.១. ឥណទានគេហដ្ឋាន

ឥណទានគេហដ្ឋានត្រូវបានផ្តល់ជូនអតិជនរូបវន្តបុគ្គលទូទៅក្នុងគោលបំណង សម្រាប់ទិញគេហដ្ឋានថ្មី ការសាងសងគេហដ្ឋានថ្មី និង ការជួសជុលកែលម្អគេហដ្ឋាន ។ ទំហំឥណទានដែលអតិថិជនអាចខ្ចីបានរហូតទៅ ៩០% នៃតម្លៃគេហដ្ឋាន តែមិនឲ្យលើសពីកម្រិត ១០% នៃមូលនិធិផ្ទាល់សុទ្ធ រយៈពេលខ្ចីរហូតដល់ ៣០ឆ្នាំ អត្រាការប្រាក់ចាប់ពី ៧% ឡើងទៅដល់ ១៦% ក្នុង១ឆ្នាំ ហើយចំណែកឯការបង់សងត្រលប់មាន២របៀបគឺសងថេររៀងរាល់ខែរវាងប្រាក់ដើម និងការប្រាក់ និងមួយទៀតសង់ដើមថេរ បូកនឹងការប្រាក់ រៀងរាល់ខែ ។

### ១.២. ឥណទានរយៈពេលខ្លី

ឥណទានរយពេលខ្លីត្រូវបានផ្តល់ជូនអតិជនជារូបវន្តបុគ្គល និងជានីតិបុគ្គលសម្រាប់តម្រូវការប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្ម ។ ទំហំឥណទានដែលអតិថិជនអាចខ្ចីបានរហូតទៅ ៩០% នៃតម្លៃទ្រព្យបញ្ចាំ តែមិនឲ្យលើសពីកម្រិត ១០% នៃមូលនិធិផ្ទាល់សុទ្ធ រយៈពេលខ្ចីរហូតដល់ ៣ឆ្នាំ អត្រាការប្រាក់រហូតដល់ ១៨% ក្នុង ១ឆ្នាំ ហើយចំណែកឯការបង់សងត្រលប់មាន៣របៀបគឺសងថេររៀងរាល់ខែរវាងប្រាក់ដើម និងការប្រាក់ និងមួយទៀតសង់ដើមថេរ បូកនឹងការប្រាក់ រៀងរាល់ខែ និងទី៣គឺសងតែការប្រាក់រាល់ខែ ប្រាក់ដើមសងចុងគ្រា ។

### ១.៣. ឥណទានរយៈពេលវែង

ឥណទានរយៈពេលវែងត្រូវបានផ្តល់ជូនអតិជនជារូបវន្តបុគ្គល និងជានីតិបុគ្គលសម្រាប់តម្រូវការប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្ម ។ ទំហំឥណទានដែលអតិថិជនអាចខ្ចីបានរហូតទៅ ៩០% នៃតម្លៃទ្រព្យបញ្ចាំ តែមិនឲ្យលើសពីកម្រិត ១០% នៃមូលនិធិផ្ទាល់សុទ្ធ រយៈពេលខ្ចីរហូតដល់ ២០ឆ្នាំ អត្រាការប្រាក់រហូតដល់ ១៨% ក្នុង១ឆ្នាំ ហើយចំណែកឯការបង់សងត្រលប់មាន៣របៀបគឺសងថេររៀងរាល់ខែរវាងប្រាក់ដើម និងការប្រាក់ និងមួយទៀតសង់ដើមថេរ បូកនឹងការប្រាក់ រៀងរាល់ខែ និងទី៣គឺសងតែការប្រាក់រាល់ខែ ប្រាក់ដើមសងចុងគ្រា ។

### ១.៤. ឥណទានសម្រាប់ទូទាត់ទំនិញ

ឥណទានសម្រាប់ទូទាត់ទំនិញត្រូវបានផ្តល់ជូនអតិជនជារូបវន្តបុគ្គល និងជានីតិបុគ្គលសម្រាប់តម្រូវការប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្ម ។ ទំហំឥណទានដែលអតិថិជនអាចខ្ចីបានរហូតទៅ ៩០% នៃតម្លៃទ្រព្យបញ្ចាំ តែមិនឲ្យលើសពីកម្រិត ១០% នៃមូលនិធិផ្ទាល់សុទ្ធ រយៈពេលខ្ចីរហូតដល់ ៥ឆ្នាំ អត្រាការប្រាក់រហូតដល់ ១៨% ក្នុង១ឆ្នាំ ហើយចំណែកឯការបង់សងត្រលប់មាន៣របៀបគឺសងថេររៀងរាល់ខែរវាងប្រាក់ដើម និងការប្រាក់ និងមួយទៀតសង់ដើមថេរ បូកនឹងការប្រាក់ រៀងរាល់ខែ និងទី៣គឺសងតែការប្រាក់រាល់ខែ ប្រាក់ដើមសងចុងគ្រា ។

### ១.៥. ឥណទាននិស្សិត

ឥណទាននិស្សិតត្រូវបានផ្តល់ជូនអតិជនជារូបវន្តបុគ្គល សម្រាប់តម្រូវការប្រើប្រាស់ក្នុងការបង់ថ្លៃក្នុងការសិក្សា ។ ទំហំឥណទានដែលអតិថិជនអាចខ្ចីបានរហូតទៅ ៩០% នៃតម្លៃទ្រព្យបញ្ចាំ ឬអាចខ្ចីដល់ ១០,០០០ ដុល្លារ តែមិនឲ្យលើសពីកម្រិត ១០% នៃមូលនិធិផ្ទាល់សុទ្ធ រយៈពេលខ្ចីរហូតដល់ ៥ឆ្នាំ អត្រាការប្រាក់រហូតដល់ ៨% ក្នុង១ឆ្នាំ ហើយចំណែកឯការបង់សងត្រលប់មាន៣របៀបគឺសងថេររៀងរាល់ខែរវាងប្រាក់ដើម និងការប្រាក់ និងមួយទៀតសង់ដើមថេរ បូកនឹងការប្រាក់ រៀងរាល់ខែ និងទី៣គឺសងតែការប្រាក់រាល់ខែ ប្រាក់ដើមសងចុងវគ្គ ។

## ២. ការគ្រប់គ្រងហានិភ័យឥណទាន

យើងឃើញថាឥណទានវាជាផលិតផលស្នូលរបស់គ្រឹះស្ថាន ហើយក៏ជាប្រភពចំណូលតែមួយគត់សម្រាប់ឲ្យអាជីវកម្មមួយនេះដំណើរការទៅមុខបាន អាចនិយាយបានថាវាជាក្បាលម៉ាស៊ីនដែលរុញឲ្យស្ថាប័នទាំងមូលអាចធ្វើដំណើរទៅមុខបាន ។ ដូច្នេះសម្រាប់ការមើលថែនូវសុខភាពឥណទានឲ្យបានល្អ វាជាកត្តាសំខាន់បំផុតរបស់គ្រឹះស្ថាន ដែលត្រូវយកចិត្តទុកដាក់ឲ្យខ្លាំងដើម្បីទទួលបាននូវគុណភាព និងប្រសិទ្ធិភាពខ្ពស់ ។

ដើម្បីឆ្លើយតបទៅនឹងការចង់បាននេះគ្រឹះស្ថានត្រូវមានការគ្រប់គ្រងឥណទានមួយច្បាស់លាស់ ត្រឹមត្រូវតាមរយៈការដាក់ចេញនូវគោលការណ៍ និងនីតិវិធីផ្សេងៗ សម្រាប់ការអនុវត្តក្នុងការគ្រប់គ្រងឥណទាន ។ ក្នុងការគ្រប់គ្រងទៅលើហានិភ័យឥណទានគឺចាប់តាំងពីពេលបញ្ចេញឥណទាន រហូតដល់ឥណទានត្រូវបានបញ្ចប់ ។

សម្រាប់ការងារគ្រប់គ្រងហានិភ័យឥណទានតាមរយៈចំនុចជាច្រើនដែលត្រូវបំពេញក្នុងការបង្ការ រួមមានឯកសារគ្រាំទ្រលក្ខណៈផ្លូវច្បាប់នានាដោយមានការដឹងលឺពីសំណាក់មេធាវីឯករាជ្យមួយ រវាងគ្រឹះស្ថានជាមួយនឹងអតិថិជន ការវាយតម្លៃលើទ្រព្យដាក់បញ្ចាំដោយក្រុមហ៊ុនមានវិជ្ជាជីវៈត្រឹមត្រូវ និងមានតម្លាភាព ការត្រួតពិនិត្យសុខភាពឥណទានមុនបញ្ចេញ និងការវាយតម្លៃឥណទានតាមបច្ចេកទេសត្រឹមត្រូវជៀសវាងហានិភ័យទៅថ្ងៃក្រោយ ។

ក្រោយពីការបញ្ចេញឥណទានក៏មានធ្វើការកត់ត្រាតាមដានយ៉ាងហ្មត់ចត់ត្រឹមត្រូវដោយបុគ្គលិកជំនាញលើអតិថិជននិមួយៗ ដើម្បីឲ្យដឹងពីព័ត៌មានអតិថិជនសងត្រលប់គ្រប់ចំនួន ឬបង់សងយឺតយ៉ាវជាដើម ។ មន្ត្រីឥណទាន ទទួលបន្ទុកត្រូវធ្វើការទំនាក់ទំនងទៅអតិថិជនដើម្បីបញ្ជាក់ពីពេលវេលាច្បាស់លាស់ក្នុងការសងត្រលប់មកគ្រឹះស្ថាន ឲ្យបានទាន់ពេល ព្រមទាំងតាមដានរាល់ស្ថានភាពសេដ្ឋកិច្ចរបស់អតិថិជនជាប្រចាំផងដែរ ។

# ជំពូកទី ៤

## សកម្មភាពបុគ្គលិកប្រចាំឆ្នាំ

## ១. ការអភិវឌ្ឍន៍ចំណេះជំនាញ និងបង្កើនសមត្ថភាពរបស់បុគ្គលិក

ការបណ្តុះបណ្តាលជាកត្តាសំខាន់មួយដែលមិនអាចខ្វះបាន ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពទៅតាមសម័យកាលដែលមានការអភិវឌ្ឍន៍ទៅមុខឥតឈប់ឈរ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក តែងតែយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលបុគ្គលិកទាំងអស់ជាប្រចាំដើម្បីពង្រឹងនូវគុណភាពសេវាកម្មដែលផ្តល់ឲ្យអតិថិជនឲ្យបានល្អប្រសើរ និងការងារមានភាពរលូនទៅមុខ ។

គ្រឹះស្ថានតែងតែមានវគ្គបណ្តុះផ្ទៃក្នុងនៅតាមនាយកដ្ឋាននិមួយៗ ដើម្បីឲ្យការងារប្រកដដោយប្រសិទ្ធិភាពខ្ពស់ ហើយមិនត្រឹមតែប៉ុណ្ណោះបុគ្គលិកជំនាញនីមួយៗក៏ត្រូវបានទទួលការយល់ដឹងនូវចំណេះជំនាញផ្សេងៗ ដែលទាក់ទងនឹងការងារ តាមរយៈសិក្ខាសាលានានានៅខាងក្រៅផងដែរ ដើម្បីពង្រឹងចំណេះដឹងឲ្យទូលំទូលាយឥតឈប់ឈ ។ ជាលទ្ធផលដើម្បីជំរុញឲ្យអង្គភាពទាំងមូលរីកចម្រើនទៅមុខ ។





## ២. ការសហការគ្នាក្នុងការបំពេញការងារ

ជាការពិតណាស់សម្រាប់វប្បធម៌ការងារធ្វើការងារជាក្រុម ចូលរួមសហការគ្នា មានការប្រាស្រ័យទាក់ទងល្អទៅវិញទៅមក ដើម្បីឲ្យមានភាពរីកចម្រើនក្នុងអង្គភាពមួយ ។ ក្នុងនោះបុគ្គលិកក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក មានការសហការគ្នាយ៉ាងល្អពីផ្នែកមួយទៅផ្នែកមួយ ចេះជួយគ្នា បំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ចេះយល់អាធ្យាស្រ័យគ្នា មានទំនាក់ទនងល្អ ក្នុងគោលបំណងធ្វើឲ្យការងារមានភាពរលូន និងមានភាពរីករាយក្នុងការងារ ។





# ជំពូកទី ៥

## របាយការណ៍សវនកម្មហិរញ្ញវត្ថុ

## ១. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង ២០១៩ ។

### ក្រុមហ៊ុន

ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក បានបង្កើតឡើងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា និង ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ក្រោមបញ្ជីពាណិជ្ជកម្មលេខ ០០០៣៩៧០៣។ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

ទីស្នាក់ការដែលបានចុះបញ្ជីរបស់ក្រុមហ៊ុនស្ថិតនៅ ផ្ទះលេខ៤០ ផ្លូវលេខ១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មជាច្រើនប្រភេទជាពិសេសសហគ្រិនខ្នាតតូច និងមធ្យមនៅកម្ពុជា ។

### លទ្ធផលប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិអាជីវកម្មរបស់ក្រុមហ៊ុនសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ ស្ថានភាពអាជីវកម្មរបស់ ក្រុមហ៊ុននាការិយបរិច្ឆេទនោះ គឺត្រូវបានបង្ហាញដែលអមនូវរបាយការណ៍ហិរញ្ញវត្ថុ។ នាការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលមិនបានប្រកាស ឬទូទាត់ភាគលាភដែលទាក់ទងនឹងប្រាក់ចំណេញឡើយ ។

### ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| លោក Lee Kok Heng Jeremiah | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ |
| លោកស្រី ហ៊ីង សោភ័ណ្ឌ | សមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ |
| លោក ឡេង សុខលី | សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ |

### សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវ ដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ នៃស្ថានភាព

ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០និងឆ្នាំ២០១៩ ព្រមទាំងលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ដែលរៀបចំដោយក្រុមប្រឹក្សាភិបាលដែលត្រូវតម្រូវឱ្យ៖

(ក) ជ្រើសរើសគោលនយោបាយគណនេយ្យ ដោយអនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាព ខ្នាតតូច និងមធ្យមដោយផ្អែកលើការវិនិច្ឆ័យនិងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព ។

(ខ) អនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកកំណត់ត្រាគណនេយ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីសន្មតយ៉ាងសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតដ៏ខ្លី ។

(ង) គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាព លើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់ដែលប៉ះពាល់លើប្រតិបត្តិការ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាព ហើយត្រូវប្រាកដថាការសម្រេចចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អមដោយ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមនិងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ជំនួសឲ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ស៊ិកស្ទី ស៊ិកស៍ ហ្វាយណែន ម.ក
Sixty Six Finance Plc.
KINGDOM OF CAMBODIA

**លោក.** Lee Kok Heng Jeremiah

ប្រធានក្រុមប្រឹក្សាភិបាល

## ២. របាយការណ៍សវនករឯករាជ្យ

### ជូនចំពោះភាគហ៊ុននិករបស់ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង ២០១៩ របាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក នាកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំនេះ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ("CIFRSs for SMRs") ព្រមទាំងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។

### មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំ គឺឯករាជ្យពីក្រុមហ៊ុន អនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ ("IESBA Code") រួមជាមួយនិងតម្រូវការ ក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹង ការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើ របាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ ។

### ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗទៀត ។ ព័ត៌មានទាំងនេះរួមមាន ព័ត៌មានដែលបានរៀបរាប់ក្នុងរបាយការណ៍ប្រចាំរបស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ប្រចាំឆ្នាំដែលត្រូវរំពឹងទុកថានឹងរួចរាល់សម្រាប់យើងបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ ប៉ុន្តែមិនរាប់បញ្ចូលចំពោះរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករយើងខ្ញុំឡើយ ។

មតិរបស់យើងខ្ញុំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទាំងស្រុងទៅលើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនបង្ហាញពីទម្រង់បែបបទនៃការធានាណាមួយ ឬធ្វើសេចក្តីសន្និដ្ឋានណាមួយឡើយ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេង ៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្ត ឬទេ ។

ប្រសិនបើ យោងតាមការងារដែលយើងបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថា បើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើ សមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិ ដោយផ្អែកលើមូលដ្ឋាននិរន្តភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តភាព និងការប្រើប្រាស់និរន្តភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករទៅលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំបានធ្វើការវិនិច្ឆ័យនិងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម ។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការ ក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំ រួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង ។
- ស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ ។

- វាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការ ប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល ។
- សេចក្តីសន្និដ្ឋាន ទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយក្រុមប្រឹក្សាភិបាល និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទងនឹងព្រឹត្តការណ៍ ឬកាលៈទេសៈទាំងឡាយណាដែលនាំឱ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឱ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់ពាក់ពន្ធ័នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើ កំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឱ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ ។
- វាយតម្លៃការបង្ហាញទូទៅ មាតិកា និងខ្លឹមសារ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ ។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញកំឡុងពេលធ្វើសវនកម្ម ។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន ។

**ហ្គ្រេន សនថុន )ខេមបូឌា( លីមីតធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

## ៣. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់៣.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ពាន់រៀល (កំណត់សម្គាល់៣.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៥.៦០១ | ២២.៦៥៦ | - | - |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ១.២៣៥ | ៤.៩៩៦ | ១៥០.៨០៩ | ៦១៤.៥៤៧ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ២៨៣.៣៣២ | ១.១៤៦.០៧៨ | ១៦៧.៧១១ | ៦៨៣.៤២២ |
| ឥណទានទៅអតិថិជន សុទ្ធ | ១០ | ១.៩៥០.២១៤ | ៧.៨៨៨.៦១៦ | - | - |
| ឥណទានទៅភាគីសម្ព័ន្ធញាតិ | ២៣ | ៣៥៧.១៩៥ | ១.៤៤៤.៨៥៤ | ២.៥៤៨.៤៣៨ | ១០.៣៨៤.៨៨៥ |
| ប្រាក់បញ្ញើតាមបទបញ្ញត្តិ | ១១ | ១៥០.០០០ | ៦០៦.៧៥០ | ១៥០.០០០ | ៦១១.២៥០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ សុទ្ធ | ១២ | ២៩.៩៣១ | ១២១.០៧១ | ៣៥.៥០១ | ១៤៤.៦៦៧ |
| ទ្រព្យអរូបី សុទ្ធ | ១៣ | ៤៧.៣៣៦ | ១៩១.៤៧៤ | - | - |
| ពន្ធពន្យារនៃទ្រព្យសកម្ម | ១៦ | ៣៦.០៩២ | ១៤៥.៩៩២ | ២០.៨៧៦ | ៨៥.០៧០ |
| ទ្រព្យសកម្មផ្សេងៗ | ១៤ | ២០.៣១៣ | ៨២.១៦៥ | ៤១.៨៤៣ | ១៧០.៥០៨ |
| **ទ្រព្យសកម្មសរុប** | | **២.៨៨១.២៤៩** | **១១.៦៥៤.៩៥២** | **៣.១១៥.១៧៨** | **១២.៦៩៤.៣៤៩** |
| **មូលធន និងបំណុល** | | | | | |
| **បំណុល** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ | ១៥ | ៣១.០៦៩ | ១២៥.៦៧៤ | ៤.៥១១ | ១៨.៣៨២ |
| ទឹកប្រាក់ជំពាក់ភាគទុនិក | ២៣ | - | - | ២០៣.០៣០ | ៨២៧.៣៤៧ |
| បំណុលពន្ធលើប្រាក់ចំណូល | ១៦ | ៤ | ១៦ | ៤៩៩ | ២.០៣៣ |
| **បំណុលសរុប** | | **៣១.០៧៣** | **១២៥.៦៩០** | **២០៨.០៤០** | **៨៤៧.៧៦២** |
| **មូលធន** | | | | | |
| ដើមទុន | ១៧ | ៣.០០០.០០០ | ១២.០០០.០០០ | ៣.០០០.០០០ | ១២.០០០.០០០ |
| ខាតបង្គរ | | (១៦០.៣៤៨) | (៦០៨.៥១១) | (៩២.៨៦២) | (៣៧៦.២៧៧) |
| ទុនបម្រុងតាមបទបញ្ញត្តិ | ១៧.១ | ១០.៥២៤ | ៤២.៦០៦ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៩៤.៥៦៧ | - | ២២២.៨៦៤ |
| **មូលធនសរុប** | | **២.៨៥០.១៧៦** | **១.១៥២៨.៩៦២** | **២.៩០៧.១៣៨** | **១១.៨៤៦.៥៨៧** |
| **មូលធន និងបំណុលសរុប** | | **២.៨៨១.២៤៩** | **១១.៦៥៤.៩៥២** | **៣.១១៥.១៧៨** | **១២.៦៩៤.៣៤៩** |

## ៤. របាយការណ៍ចំណូលលម្អិត

| | កំណត់សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) |
| ចំណូលការប្រាក់ | ១៨ | ១៥៣.៧៧២ | ៦២៦.៩២៨ | ៤៩.២៥២ | ១៩៩.៥៦៩ |
| ចំណូលប្រតិបត្តិការផ្សេងទៀត | ១៩ | ១៧.៥៤៩ | ៧១.៥៤៧ | ៦០០ | ២.៤៣១ |
| **ចំណូលប្រតិបត្តិការសរុប** | | **១៧១.៣២១** | **៦៩៨.៤៧៥** | **៤៩.៨៥២** | **២០២.០០០** |
| សំវិធានធនសម្រាប់ឥណទាន | ៧ និង ៩ | (១០.២៨២) | (៤១.៩២០) | (១.៦៩៤) | (៦.៨៦៤) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២០ | (២២៨.៦៧៦) | (៩៣២.៣១២) | (១៥៣.៩២១) | (៦២៣.៦៨៨) |
| ចំណាយផ្សេងៗ | ២១ | (២.៨៣៨) | (១១.៥៧០) | (៧.៤៧៦) | (៣០.២៩៣) |
| **ខាតបង់មុនគិតពន្ធលើប្រាក់ចំណូល** | | **(៧០.៤៧៥)** | **(២៨៧.៣២៧)** | **(១១៣.២៣៩)** | **(៤៥៨.៨៤៥)** |
| អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណូល | ១៦ | ១៣.៥១៣ | ៥៥.០៩៣ | ២០.៣៧៧ | ៨២.៥៦៨ |
| **ខាតក្នុងឆ្នាំ** | | **(៥៦.៩៦២)** | **(២៣២.២៣៤)** | **(៩២.៨៦២)** | **(៣៧៦.២៧៧)** |
| **ចំណូលលម្អិតផ្សេងៗ** | | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១២៨.២៩៧) | - | ២២២.៨៦៤ |
| **ចំណូលពេញលេញក្នុងឆ្នាំសរុប** | | **(៥៦.៩៦២)** | **(៣៦០.៥៣២)** | **(៩២.៨៦២)** | **(១៥៣.៤១៣)** |

## ៥. របាយការណ៍បម្រែបម្រួលមូលធន

| | | ដើមទុន | | ខាតបង្គរ | | ទុនបម្រុងបទបញ្ញត្តិ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | មូលធនសរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) |
| សមតុល្យ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | | ៣.០០០.០០០ | ១២.០០០.០០០ | (៩២.៨៦២) | (៣៧៦.២៧៧) | - | - | ២២២.៨៦៤ | ២.៩០៧.១៣៨ | ១១.៨៤៦.៥៨៧ |
| ខាតសុទ្ធក្នុងឆ្នាំ | | - | - | (៥៦.៩៦២) | (២៣២.២៣៤) | - | - | - | (៥៦.៩៦២) | (២៣២.២៣៤) |
| ទុនបម្រុងបទបញ្ញត្តិ | ១៦.១ | - | - | (១០.៥២៤) | - | ១០.៥២៤ | ៤២.៩០៦ | - | - | ៤២.៩០៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | (១២៨.២៩៧) | - | (១២៨. ២៩៧) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | | **៣.០០០.០០០** | **១២.០០០.០០០** | **(១៦០.៣៤៨)** | **(៦០៨.៥១១)** | **១០.៥២៤** | **៤២.៩០៦** | **៩៤.៥៦៧** | **២.៨៥០.១៧៦** | **១១.៥២៨.៩៦២** |
| វិភាគទានដើមទុន | ១៦ | ៣.០០០.០០០ | ១២.០០០.០០០ | - | - | - | - | - | ៣.០០០.០០០ | ១២.០០០.០០០ |
